# ព្រះម៉ែកាឡីឬព្រះម៉ែកល្ប៍

ក្នុងលក្ខខ័ណៈជាសកល ព្រះម៉ែកាឡី ជាអទិទេពនៃកល្ប៍ ឬពេល ឬវាលវដ្តសង្សា។ គ្រប់វិនាទីដែលដើរទៅមុខ គឺកំពុងរុញច្រានជីវិតមនុស្សសត្វឆ្ពោះទៅរកព្រហ្មលិខិតឬវាលវដ្តសង្សា កើតចាស់ឈឺស្លាប់។ សេចក្តីស្លាប់នៅរង់ឃ្លាំចាំមើលយើងគ្រប់វិនាទី និងគ្រប់កន្លែង។ គ្រប់វិនាទីដែលដើរទៅមុខ អ្វីៗត្រូវពុករលួយឆ្ពោះទៅរកមរណាដើម្បីបង្កើតជីវិតជា ថ្មី។ គ្មាននរណាម្នាក់អាចប្រឆាំងនឹងច្បាប់ធម្មជាតិមួយនេះ សូម្បីពពួកព្រះក៏ស្ថិតនៅក្រោមច្បាប់នេះដែរ។ ដោយហេតុទាំងនេះហើយបានជានៅក្នុងសាសនាវេទនិងព្រហ្មញ្ញសាសនា គេចាត់ទុកព្រះម៉ែកាឡី ជាអទិទេពនៃសេចក្តីស្លាប់(Dieu de la mort) តែក៏តំណាងអោយជីវិតក្រោយសេចក្តីស្លាប់(La renaissance éternelle) សំដៅលើតួអង្គព្រះឥស្វារះ អទិទេពរ បំផ្លាញលោក និងបង្កើតលោក។ មនុស្សដែលមិនបានយល់ តែងចាត់ទុកព្រះម៉ែកាឡី ជាអវតាអវិជ្ជាមានរបស់ព្រះឥស្វារៈ និមិត្តរូបនៃការបំផ្លាញលោក ផ្ទុយនឹងតួអង្គព្រះឥសូរ ដែលជាអទិទេពរសាងលោក តំណាងដោយពីរ៉ាប៊ិត(La mort de l’ancien monde/corps et la renaissance, le nouveau le monde, selon concept égyptien) ប៉ុន្តែនៅក្នុងវេទ ពីរ៉ាប៊ិត ផ្កាប់ផ្ងា តំណាងអោយការគ្រាស់ដឹងនិងការសាងលោករបស់ព្រះឥសូរ ។

គំនូរតំណាងព្រះនាងត្រូវបានគេគូរជារូបបិសាចពណ៌ខៀវស្វាយដ៏គួរអោយខ្លាច មានដៃ៤ឬច្រើនជាងនេះ ពាក់ក្បាលខ្មោចជាខ្សែក នៅចង្កេះមានសុទ្ធតែដៃមនុស្ស។ ដៃព្រះនាងកាន់ក្បាលមនុស្សដែលទើបតែកាត់កហូរឈាមកក្លាក់ ដៃមួយទៀតកាន់កង្វេរពិឃាត កំពុងរត់តាមសម្លាប់មនុស្ស ប្រៀងបាននឹងការរំកិលនៃវេនវេលាដែលរុញជីវិតលើលោកទៅរក កើត ចាស់ ឈឺ ស្លាប់ និងការកើតឡើងវិញ..។ ជើងព្រះនាងជាន់លើសាកសពព្រះឥស្វារៈឬព្រះឥសូរ។ គឺរូបភាពនេះហើយដែលពួកពុទ្ធសាសនា យកទៅប្រឌិតជារឿងមារផ្ចាញ់សមនគោតម ហើយទីបំផុតត្រូវចាញ់សមនគោតមទើបលុតជង្គង់សុំសមនគោតមប្រោសជីវិត។ល។ នេះជាការប្រមាថព្រះដ៏ធ្ងន់ធ្ងរ។

នៅតំបន់មេស៊ូប៉ូតាមី ព្រះនាងមានឈ្មោះថា *Ereshkigal* ជាបុត្រីច្បងរបស់អទិទេពអង្គលីលឬអ៊ើល និងត្រូវជាបងស្រីរបស់ព្រះនាងអ៊ីសតាអ៊ីណាន់ណាឬព្រះនាងឥន្ទ្រ។ ស្វាមីព្រះនាងឈ្មោះ *Nergal*។ ពួកក្រិកដែលបានចម្លងទេវកថានេះ យកទៅកែរសម្រួលតាមបែបក្រិកនិងបានអោយឈ្មោះថា **Perséphone** ឬ **Coré** មានស្វាមីឈ្មោះ Hadès។ អារ្យធម៌ផ្សេងៗដែលកើតក្រោយៗ ក៏បានចម្លងយកទៅកែសម្រួលធ្វើជារបស់គេរៀងៗខ្លួន ពេលខ្លះស្ទើរបាត់ភាពដើមទាំងស្រុងទៅហើយ នៅសល់តែគោលធំៗប៉ុណ្ណោះ ដែលមានតែមនុស្សមានញាណខ្ពស់បំផុតបំផុតប៉ុណ្ណោះអាចយល់ឬមើលឃើញ..

ជាលក្ខខ័ណៈបុគ្គល កាឡី គឺជាមរតកនៃសភាវៈអាក្រក់ដែលមាននៅក្នុងមនុស្សម្នាក់ៗ។ នៅពេលដែលមនុស្សចិញ្ចឹមបណ្តុះសភាវៈអាក្រក់ឬលុះក្នុងផ្លូវអាក្រក់ សភាវៈល្អក៏ចេះតែរួញតូចទៅៗរហូតស្លាប់តែម្តងដែលស្មើនឹងការសម្លាប់ព្រះឬពន្លឺជីវិតដូចរូបភាពកាឡីជាន់លើព្រះឥសូរ។ ជីវិតមនុស្សបែបនេះ គ្របដណ្តប់កប់ក្នុងអាត្មានិយម អញនិយម(Ego) ក្នុងភាពទុច្ចរិត អន្ធកាល អវិជ្ជា ក្លាយជាសាហាវកាច ហុតឈាមមនុស្សដូចគ្នាដូចបិសាច ដែលជាជីវភាពប្រចាំថ្ងៃធម្មតារបស់ពួកគេ រហូតលែងដឹងថា អំពើកំណាចឃោរឃៅដែលខ្លួនកំពុងសាង វាបះពាល់និងបង្ករទុក្ខទោសដល់ជីវិតអ្នកដ៏ទៃ។ ក្នុងនោះរាប់ទាំង អំពើអវិជ្ជមានទាំងឡាយ៖ ចិត្តដែលលោភលន់ និន្ទាឈ្នានីស ប្រមាថ មុសារ មិនដឹងខុសត្រូវ ងងឹតអន្ធកាល អវិជ្ជា មិនចេះបែងចែកអាក្រក់ល្អ និងចិត្តចង្អៀតចង្អល់។ល។ ដែលសុទ្ធតែជាផ្នែកនៃអំពើអាក្រក់ឬកម្មាកាឡី។ មនុស្សបែបនេះ មុននឹងថា កាឡីគួរអោយខ្លាច សូមឆ្លុះកញ្ចក់មើលខ្លួនឯងជាមុនសិន ព្រោះមនុស្សដែលចេញពីកញ្ចក់នោះអាក្រក់ជាងដូចឬជាងរូបភាពកាឡីទៅទៀត ហើយអំពើអាក្រក់ដែលបុគ្គលបែបនេះបានកសាង មិនត្រឹមតែធ្វើអោយជីវិតជននោះលុះក្នុងកម្មអាក្រក់សម្រាប់តែខ្លួនឯងប៉ុណ្ណោះទេ តែត្រូវបានចារក្នុងឈាមតពូជកូនចៅតទៅដែលធ្វើអោយពូជមនុស្សបែបនេះ បែកចេញពីព្រះឆ្ងាយទៅៗ...។ ដូចគ្នាដែរ ពេលដែលមនុស្សរស់ក្រោមក្រិតក្រមគុណធម៌ សច្ចធម៌ ក្រោមគតិបណ្ឌិត ត្រេតត្រកាលនឹងការសាងអំពើល្អ ប្រយុទ្ធប្រឆាំងនឹងអំពើអាក្រក់ ទាំងក្នុងខ្លួននឹងក្រៅខ្លួន រហូតលែងមានកន្លែងសម្រាប់អំពើអាក្រក់ ឬរហូតអំពើអាក្រក់ខ្លាចលែងហ៊ានមកក្បែរបាន ពេលនោះគេនឹង បានឃើញព្រះ ហើយគេនឹងរស់ក្នុងការពិតនៃព្រះ។ សភាវៈអាក្រក់និងសភវៈល្អ ជាមរតកដែលព្រះបានប្រគល់អោយមនុស្ស ហើយមនុស្សត្រូវមានភារកិច្ចប្រយុទ្ធប្រឆាំងនិងធ្វើការជ្រើសរើសដោយខ្លួនឯងក្នុងដំណើរជិវិតរបស់គេ ថាតើគេជ្រើសរើសផ្លូវទៅនរកអវចី និងអវិជ្ជា ឬត្រលប់ទៅព្រះពន្លឺវិញ? ពេលដែលគេច្បាំងឈ្នះអំពើអាក្រក់ និងអវិជ្ជា គេនឹងបានឃើញព្រះពន្លឺនិងបញ្ញាដ៏អស្ចារ្យរបស់ព្រះ ព្រមទាំងខ្លឹមសារជីវិត និង សុភមង្គលឥតម៉ងសៅទាំងផ្លូវកាយនិងចិត្ត ហៅថា ម៉ុកស្សា។

ទាំងនេះជាគំរូជាគោលៗដែលពួកបស្ចឹមប្រទេសយកជាមាគ៌ា ដើម្បីសាងសង្គមគុណធម៌មួយដែលមនុស្សរស់នៅក្នុងសង្គមស្មើភាព មានគុណធម៌ មានភាតរភាព ចេះអត់អោនគ្នា មានការគោរពសិទ្ធិបុគ្គលនិងច្បាប់រដ្ឋ និងមានច្បាប់ការពារមនុស្សទន់ខ្សោយ ក្រីក្រ ដែលផ្ទុយពីសង្គមនរកតិរិច្ឆានក្រោមឥទ្ធិពលចិននិងយួន ដែលប្រើតែអំណាចបុណ្យសក្តិ លុយកាក់ ជិះជាន់ ប្រមាថ អ្នកទន់ខ្សោយក្រីក្រ.... ចន្ទ្រ

៥កុម្ភៈ២០២១




